ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់ព្រឹទ្ធសភា

# ប្រចាំខែធ្នូ ឆ្នាំ២០១៩

*នៅក្នុងខែធ្នូ ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ*

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន :**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨ ប្រចាំឆ្នាំ២០១៩

-អនុញ្ញាតឱ្យឯកឧត្តម Troung Hoa Binh ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឱ្យលោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឱ្យលោកជំទាវ Angela Corcoran ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសម និងជម្រាបលា

-អនុញ្ញាតឱ្យឯកឧត្តម Saud F.M.AL Suwelim ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អនុញ្ញាតឱ្យឯកឧត្តម Amjad All sher ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថានប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញជាអធិបតីក្នុងពិធីប្រារព្ធខួបគម្រប់៦០ឆ្នាំ នៃឱសថតីណាល់ និងការប្រកាសលទ្ធផលពានរង្វាន់តីណាល់ឆ្នាំ២០១៩ នៅសហគ្រាសផលិតឱសថប៉េ.ប៉េ.អឹម ស្ថិតនៅភូមិព្រៃជីសាក់ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាល និងទទួលទានអាហារថ្ងៃត្រង់ជាមួយអតីតយុទ្ធជនយុទ្ធនារី ភូមិភាគឥសាន ក្នុងបរិយាកាសរីករាយ និងពោរពេញទៅដោយមនោសញ្ចេតនានឹករលឹក ស្រលាញ់រាប់អានយ៉ាងជ្រាលជ្រៅ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៦ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន២២ច្បាប់ ។

**១.២-ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងអង្គមីទ្ទិញខួបអនុស្សាវរីយ៍រណសិរ្ស២ធ្នូ លើកទី៤១ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៣ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន៣០ច្បាប់។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាគណៈអធិបតីអបអរសាទរមីទ្ទិញខួបអនុស្សាវរីយ៍ ២ធ្នូ លើកទី៤១ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅភូមិកណ្តាល ឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ព្រមទាំងឱ្យក្រុមការងារនាំយកប្រជាពលរដ្ឋមួយរូប ដែលមានស្ថានភាពជំងឺធ្ងន់ធ្ងរយកមកសម្រាកព្យាបាលនៅមន្ទីរពេទ្យឯកជននៅទីក្រុងភ្នំពេញ និងបានឧបត្ថម្ភលើការចំណាយទាំងស្រុង

-អញ្ជើញដឹកនាំប្រជុំពិភាក្សាការងាររៀបចំពិធីបុណ្យខួបលើកទី៤១នៃទិវាជ័យជម្នះ៧ មករា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៨ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន៣៥ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោមៈ

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មព្រឹទ្ធសភាសុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦

៤-កំណត់របៀបវារៈ និងកាលបរិច្ឆេទសម័យប្រជុំព្រឹទ្ធសភាលើកទី៤ នីតិកាលទី៤។

**៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា**

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គចំនួន០១លើកដើម្បីពិនិត្យ និងឱ្យយោបល់លើ ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

៣-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ។

## ៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែធ្នូនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

### ៤.១-មុខងារនីតិកម្ម

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរ-គណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ។

### ៤.២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-អញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ការងារនៅមូលដ្ឋានជាមួយក្រុមប្រឹក្សាឃុំ ស្មៀន នគរបាលឃុំ ទូទាំងស្រុកពាមជរ ខេត្តព្រៃវែង

-អញ្ជើញចុះជួបជាមួយក្រុមប្រឹក្សាសង្កាត់ និងមេភូមិនៃសង្កាត់បឹងធំ ដើម្បីពិនិត្យអំពីបញ្ជីឈ្មោះបោះឆ្នោត និងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ព្រមទាំងពិនិត្យទីតាំងជីកអណ្តូងទឹកក្នុងវិទ្យាល័យបឹងធំ ផ្អែកតាមស្មារតីនៃវេទិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ឆ្នាំ២០១៩ ស្តីពីការផ្តល់អណ្តូងទឹកស្អាតដល់តំបន់ជាយក្រុង ដែលបណ្តាញទឹកស្អាតមិនទាន់ទៅដល់ ស្ថិតក្នុងសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ

-អញ្ជើញចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត និងគណៈអភិបាលខេត្ត ដើម្បីជម្រុញ និងលើកកម្ពស់ការផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព នៅខេត្តបាត់ដំបង ។

### ៤.៣-មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន ០៨ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៨ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការដើម្បីជូនជ្រាបចំនួន០១ករណី

-បានរៀបចំវេទិកាស្តីពី ការតម្រង់ទិសដល់យុវតីឆ្ពោះទៅភាពជាអ្នកដឹកនាំ

-អញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារអភិវឌ្ឍន៍ និងលើកទិសដៅការងារបន្តរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍របស់ខេត្តរតនគីរីនិងខេត្តឧត្តរមានជ័យ

-អញ្ជើញទស្សនកិច្ចសិក្សា និងត្រួតពិនិត្យដែនរដ្ឋបាល និងគម្រោង អភិរក្សតំបន់ការពារធម្មជាតិក្នុងដែនជម្រកសត្វព្រៃព្រៃឡង់

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការបញ្ជ្រាបការយល់ដឹង និងបង្កើតយន្តការការពារ និងគ្រប់គ្រងជំងឺមិនឆ្លង

-អញ្ជើញចូលរួមប្រជុំពិភាក្សាស្តីពី គម្រោងបែងចែកកញ្ចប់ថវិកាឆ្នាំ២០២០ របស់ព្រឹទ្ធសភា

-អញ្ជើញចូលរួមក្នុងពិធីផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពី ការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

-អញ្ជើញចូលរួមស្តាប់បទបង្ហាញរបស់វិទ្យាស្ថានសភាកម្ពុជា (PIC)ស្តីពី ទិដ្ឋភាពទូទៅលើការបែងចែកថវិកានិងទូទាត់ថវិកានៅថ្នាក់ក្រោមជាតិសម្រាប់ការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន

-អញ្ជើញចូលរួមក្នុងពិធីអបអរសាទរសន្និបាតបូកសរុបការងារអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពី ពិការភាព២០១៩-២០២៣ ព្រមទាំងទិវាជនមានពិការភាពកម្ពុជាលើកទី២១ និងអន្តរជាតិលើកទី៣៧ ក្រោមប្រធានបទលុបបំបាត់ឧបសគ្គរាំងជនមានពិការភាព ដើម្បីសង្គមមួយប្រកបដោយបរិយាបន្ន

-អញ្ជើញចូលរួមអង្គមីទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤១ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា(២ធ្នូ១៩៧៨-២ធ្នូ ២០១៩)

-អញ្ជើញចូលរួមពិធីតាំងសៀវភៅស្តីពី ដំណើរឆ្ពោះទៅមុខនៃចំណងមិត្តភាពកម្ពុជា-ឥណ្ឌូនេស៊ីខួបលើកទី៦០

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៨៨លើក ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ ជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព

សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨៩លើក ។

**៥- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តម **ជា ជេដ្ឋ** អញ្ជើញចូលរួមសន្និសីទសកលលោកលើកទី៧ របស់សមាជិកសភាប្រឆាំងនឹងអំពើពុករលួយ(GOPAC) នៅទីក្រុងដូហា ប្រទេសកាតា

-ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** និងឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញចូលរួមកិច្ចប្រជុំលើកទី៩នៃសភាប្រើប្រាស់ភាសាបារាំងតំបន់អាស៊ីប៉ាស៊ីហ្វិច នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី២ និងមហាសន្និបាតសភាអាស៊ី(APA) លើកទី១២ស្តីពី តួនាទីកិច្ចសហប្រតិបត្តិការពហុភាគីក្នុងចំណោមបណ្តាសភាអាស៊ី នៅទីក្រុង Antalya នៃប្រទេសតួកគី

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញជួបពិភាក្សាការងារជាមួយអ្នកវិនិយោគជនជាតិកូរ៉េ ដឹកនាំដោយលោក LEE CHANGHOON Managing Director(CEO) HYUNDAI CORPORATION (CAMBODIA) CO,LTD ដើម្បីជម្រុញការនាំចេញផ្លែស្វាយចេញពីព្រះរាជាណាចក្រកម្ពុជា ចូលទីផ្សារប្រទេសកូរ៉េខាងត្បូងឱ្យបានចំនួនកាន់តែច្រើន ។

ថ្ងៃ សុក្រ ១៣រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

**ជ. ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ